*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។ BAKC-JFBA Seminar, March 15, 2018 (Miha Isoi)*

( ពន្ធដាក់ពាក្យសុំចំនួន ៥០០០រៀល )

# ពាក្យសុំសេចក្តីរាយការណ៍ពីស្ថានភាពរបស់កូន និង ពាក្យសុំចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន

**គោរពជូន**

ប្រធានសាលាដំបូងរាជធានីភ្នំពេញ

អ្នកដាក់ពាក្យសុំ [ ក ] (ផ្ទះលេខ ៣៤ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ ភ្នំពេញ)

ភាគីម្ខាងទៀត [ ខ ] ( ផ្ទះលេខ ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ)

កូនដែលជាអនីតិជន (គ) (កូនស្រីច្បង រស់នៅជាមួយភាគីម្ខាងទៀត កើតនៅថ្ងៃទី ២ ខែមេសា ឆ្នាំ ២០០៧)

១. ស្នើសុំតុលាការវិនិច្ឆ័យលើ

ក. ភាគីម្ខាងទៀត ត្រូវធ្វើរបាយការណ៍អំពីកូនស្រី គ ជូនអ្នកដាក់ពាក្យសុំ នៅរៀងរាល់ចុងខែម្តង រហូតដល់ខែដែល កូនស្រី គ ឈានដល់អាយុ ១៨ឆ្នាំ។

ខ. បង្គាប់ឲ្យភាគីម្ខាងទៀតរាយការណ៍អំពីស្ថានភាពរបស់កូនស្រី គ ១ខែម្តង។

គ. បង្គាប់ឲ្យភាគីម្ខាងទៀតអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំចូលជួបកូនស្រី ២ខែម្តង។

២. មូលហេតុនៃការដាក់ពាក្យសុំ

ក. អ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀតនៃពាក្យសុំបានលែងលះគ្នាតាមការព្រមព្រៀងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨។

ខ. ភាគីទាំងពីរបានបង្កើតកូនស្រីម្នាក់នៅថ្ងៃទី ២ ខែមេសា ឆ្នាំ២០០៧ ដោយគិតមកដល់ពេលនេះមានអាយុ ១០ឆ្នាំហើយ។

គ. អ្នកដែលមានអំណាចមេបាលើកូនស្រី គ គឺភាគីម្ខាងទៀត ហើយកូនស្រី គ ស្ថិតក្រោមការមើលថែទាំរបស់ភាគីម្ខាងទៀតនៃពាក្យសុំ។

ឃ. អ្នកដាក់ពាក្យសុំមានបំណងចង់ទទួលបាននូវសេចក្តីរាយការណ៍ពីស្ថានភាពរបស់កូនរៀងរាល់មួយខែម្តង និងមានបំណងចូលជួបប្រាស្រ័យទាក់ទងជាមួយកូនស្រីខ្លួន រៀងរាល់ពីរខែម្តង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨

អ្នកដាក់ពាក្យសុំ ក

*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។ BAKC-JFBA Seminar, March 15, 2018 (Miha Isoi)*

អ្នកតំណាងរបស់អ្នកដាក់ពាក្យសុំ ក លោកមេធាវី ឃ
ការិយាល័យមេធាវី Apple
អាគារវឌ្ឍនៈជាន់ទី ៣៩ លេខ ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

## ឯកសារភ្ជាប់

១. សំបុត្រកំណើតរបស់ គ